**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

## កិច្ចសន្យាព្យួរកិច្ចសន្យាការងាររយៈពេល ៥៩ ថ្ងៃ

**(ចាប់ថ្ងៃទី ០១ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២)**

### ធ្វើឡើងរវាង

ក្រុមហ៊ុនត្រូពីកាណា រីស្សត អែនកាស៊ីណូ (ប៉ោយប៉ែត អ៊ិនធីណេសិនណល់ ក្លឹប) ដែលមាន លោក**គង់ សុជានី** អាយុ ៤៨ ឆ្នាំ សញ្ជាតិខ្មែរ មានតួនាទីជាជំនួយការប្រធានធនធានមនុស្សជាតំណាង តទៅហៅថាភាគី "ក"។

**និង**

បុគ្គលិកកម្មកររបស់ក្រុមហ៊ុនត្រូពីកាណា រីស្សត អែនកាស៊ីណូ (ប៉ោយប៉ែត អ៊ិនធីណេសិនណល់ ក្លឹប) ចំនួន ៨៣០ នាក់ ដែលតំណាងដោយៈ

១. សួស ឆាន ភេទប្រុស ជាប្រធានក្រុមសន្តិសុខ
២. សុខ សាខនថៃលីហ្សា ភេទប្រុស ជាជំនួយការប្រធានផ្នែកចុងភៅ
៣. ជុំ វុទ្ធី ភេទប្រុស ប្រធានក្រុមបំរើអាហារនិងភេសជ្ជៈ
៤. វេត ជីវ័ន្ត ភេទប្រុស ជាជំនួយការប្រធានផ្នែកចុងភៅ

តទៅហៅថាភាគី "ខ"។

ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យាព្យួរកិច្ចសន្យាការងារនេះដូចតទៅ:

**ដោយហេតុថា:** ភាគី "ក" មិនទាន់អាចដំណើរការអាជីវកម្មវិញបាន ដោយសារស្ថានភាពមេរោគ កូវីត-១៩ នៅតែបន្តគម្រាមកំហែងទូទាំងពិភពលោក និងដោយសារភាគីថៃនៅតែមិនទាន់បើកព្រំដែនរបស់ខ្លួនជាមួយនឹងកម្ពុជានៅឡើយ។

**ប្រការ១ៈ** ភាគី "ក" បានសម្រេចព្យួរកិច្ចសន្យាការងារបុគ្គលិកចំនួន ៨៣០នាក់ជាបន្តទៀតរយៈពេល ៥៩ ថ្ងៃ ដោយរាប់គិតចាប់ថ្ងៃទី ០១ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។

**ប្រការ២ៈ** ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យានេះ ភាគី "ក" នឹងមិនមានផ្តល់ប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមអ្វីទាំងអស់ លើកលែងតែផលប្រយោជន៍ដែលទាក់ទងនឹងប.ស.ស.តែប៉ុណ្ណោះ។

**ប្រការ៣ៈ** ភាគី "ខ" យល់ព្រមទៅតាមខ្លឹមសារដែលមានចែងនៅក្នុងប្រការ១ និងប្រការ២ ឥតមានជំទាស់អ្វីឡើយ។

TROPICANA
Resort & Casino

**ប្រការ៤៖** កិច្ចសន្យានេះអាចនឹងត្រូវកែប្រែ បញ្ចប់មុនរយៈពេលកំណត់ ឬពន្យារពេលបន្តទៀតទៅតាមសភាពជាក់ស្តែងនៃការបិទបើកព្រំដែននៃប្រទេសទាំងពីរ និងសភាពនៃការចម្លងរបស់មេរោគកូវីត-១៩។

**ប្រការ៥៖** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០២(ពីរ)ច្បាប់ មានតម្លៃអនុវត្តពេញលក្ខណៈច្បាប់ដូចគ្នា ហើយរក្សាទុកនៅភាគី "ក" ០១ ច្បាប់ និងភាគី "ខ" ០១ ច្បាប់។

កិច្ចសន្យានេះចូលជាធរមានចាប់ពីថ្ងៃផ្តិតមេដៃលើកិច្ចសន្យារួចភ្លាម ។

ធ្វើនៅប៉ោយប៉ែត, ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០២១

ស្នាមមេដៃស្តាំភាគី "ក" ស្នាមមេដៃស្តាំភាគី "ខ"

TROPICANA Resort & Casino

គង់ សុផានី សួស ឆាន សុខ សាខនថៃលីហ្សា ជុំ វុទ្ធី វេត ជីវ័ន្ត